ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង វណ្ណៈ
២-មេធាវី អ៊ឹង គិរិយា
៣-មេធាវី កែត ឃី
៤-មេធាវី អ៊ឹច ប៊ុលី
៥-មេធាវី ខៀវ សំបូរ
៦-មេធាវី ជា សុគន្ធន
៧-មេធាវី សាន់ ជួយ
៨-មេធាវី ថាន ផានិត
៩-មេធាវី ជូ ចាន់ធីរ៉ា
១០-មេធាវី កេង សុម៉ាឡា
១១-មេធាវី ម៉ី ឧសភា
១២-មេធាវី សេង សុខឃីម
១៣-មេធាវី លីវ សុវណ្ណា
១៤-មេធាវី ឈីវ គិរម្យ
១៥-មេធាវី សំ សុគង់
១៦-មេធាវី នង មាននួ
១៧-មេធាវី អ៊ូ ធីតាពៅ
១៨-មេធាវី លី ពីង
១៩-មេធាវី យឹម វិសុត្រ
២០-មេធាវី លីម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហូ លីហួច
២៣-មេធាវី វ៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ កញ្ញា
២៦-មេធាវី ម៉ុន វិមានចំប៉ា
២៧-មេធាវី ឈី សម្បត្តិ

លេខ: ០៤១ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការអនុញ្ញាតឱ្យប្តូរគ្រូកម្មសិក្សា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញសេចក្តីសម្រេចលេខ ៤១៥/សសគម/១៥ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ របស់គណៈមេធាវី ស្តីពីការអនុញ្ញាតឱ្យចូលប្រកបវិជ្ជាជីវៈជាមេធាវីកម្មសិក្សា
- យោងតាមសំណើរបស់សាមីខ្លួន ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦
- យោងតាមការសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី នាសម័យប្រជុំថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦។

## ស ម្រេ ច

**ប្រការ ១.-** អនុញ្ញាតឱ្យលោកមេធាវី **រឿន ពិសី** អត្តលេខ **១១៣៤ T** ប្តូរគ្រូកម្មសិក្សាពីលោកមេធាវី **លឹម ច័ន្ទប៊ុនកែវ** មកលោកមេធាវី **រស់ ផល្លា** វិញ ដែលមានការិយាល័យឈ្មោះ **ការិយាល័យមេធាវី អិល ឌី អរ** មានអាសយដ្ឋានស្ថិតនៅ**អគារលេខ ៣៥ ផ្លូវលេខ ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ** ចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះតទៅ។

**ប្រការ ២ .-** - រាល់ទំនាក់ទំនង និង គ្រប់លិខិតរបស់កម្មសិក្សាការី ដែលធ្វើឡើងក្នុងក្របខ័ណ្ឌប្រកបវិជ្ជាជីវៈរបស់ខ្លួន ត្រូវមានហត្ថលេខាយល់ព្រមពីគ្រូកម្មសិក្សា។

- គ្រប់ការងារកម្មសិក្សារបស់កម្មសិក្សាការី ស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវផ្ទាល់របស់គ្រូកម្មសិក្សា។
- ចប់រយៈពេលកម្មសិក្សា កម្មសិក្សាការី ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលការងាររបស់ខ្លួន ដោយភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងអស់ សម្រាប់ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវី ពិនិត្យ និងសម្រេច។

**ប្រការ ៣ .-** របាយការណ៍បញ្ចប់កម្មសិក្សាក្នុងរយៈពេលពី**ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ រហូតដល់ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦** ត្រូវមានការបញ្ជាក់ពីគ្រូកម្មសិក្សាចាស់ (លោកមេធាវី **លឹម ច័ន្ទប៊ុនកែវ**) ហើយចាប់ពីថ្ងៃទី**១៤ ខែមីនា ឆ្នាំ២០១៦** រហូតដល់ចប់កម្មសិក្សា ត្រូវមានការបញ្ជាក់ពីគ្រូកម្មសិក្សាថ្មី (លោកមេធាវី **រស់ ផល្លា**)។

**ប្រការ ៤ .-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥ .-** អគ្គលេខាធិការ អគ្គហេរញ្ញិក និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន ។

ORDRE DES AVOCATS DU ROYAUME DU CAMBODGE

**មេធាវី.ប៊ុន ហ៊ុន**

**ចម្លងជូន :**

-ក្រុមប្រឹក្សាគណៈមេធាវី

-លោកមេធាវី **លឹម ច័ន្ទប៊ុនកែវ**

-លោកមេធាវី **រស់ ផល្លា**

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

ចូល

-លេខ: 3621

-ម៉ោង: 11:30

-ថ្ងៃ ខែ ឆ្នាំ: 24.02.16

-បញ្ជូន:

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំប្តូរគ្រូកម្មសិក្សា

ខ្ញុំបាទឈ្មោះ **រឿន ពិសី** ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ១១៣៩T មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ៣៨E ផ្លូវលេខ E ភូមិក្រាំងអង្រ្កង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សូមគោរពចូលមក**

**លោកប្រធានគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា**

*សូមទានជ្រាប* ។

**កម្មវត្ថុ** : សំណើសុំប្តូរគ្រូកម្មសិក្សាពីលោកមេធាវី **លឹម ច័ន្ទម៉ុនកែវ** ទៅលោកមេធាវី **រស់ ផល្លា** ។

**យោង** : -ចំណារឯកភាព ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ របស់លោកមេធាវី **លឹម ច័ន្ទម៉ុនកែវ** ។

-ចំណារឯកភាព ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ របស់លោកមេធាវី **រស់ ផល្លា** ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូនលោកប្រធាន មេត្តាជ្រាបថា : រយៈពេលកន្លងមកខ្ញុំបាទបានធ្វើកម្មសិក្សានៅក្នុងការិយាល័យ **ក្រុមមេធាវីអង្គរ** ជាមួយលោកមេធាវី **លឹម ច័ន្ទម៉ុនកែវ** ។ ដូច្នេះដើម្បីជាការផ្លាស់ប្តូរបទពិសោធន៍ការងារមួយចំនួន ខ្ញុំបាទស្នើសុំប្តូរគ្រូកម្មសិក្សាពីលោកមេធាវី **លឹម ច័ន្ទម៉ុនកែវ** ទៅលោកមេធាវី **រស់ ផល្លា** វិញ ដើម្បីធ្វើគ្រូកម្មសិក្សាបន្តទៀត ដែលមានការិយាល័យឈ្មោះការិយាល័យមេធាវី **LDR** មានទីតាំងស្ថិតនៅអាគារលេខ ៣៥CD ផ្លូវលេខ ២៧១ សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម លោកប្រធាន មេត្តាពិនិត្យ-សម្រេច ដោយក្តីអនុគ្រោះ ។

សូម លោកប្រធាន មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៦

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
មេធាវី
AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

**មេធាវី.រឿន ពិសី**

សូមជូនភ្ជាប់មកជាមួយនូវៈ

-ពាក្យស្នើសុំដែលមានការឯកភាពពីគ្រូកម្មសិក្សាចាស់ ០១ច្បាប់

-ពាក្យស្នើសុំដែលមានការឯកភាពពីគ្រូកម្មសិក្សាថ្មី ០១ច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>ពាក្យស្នើសុំប្តូរគ្រូកម្មសិក្សា</u>

ខ្ញុំបាទឈ្មោះ **រឿន ពិសី** ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ១១៣៤T មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ៣៨E ផ្លូវលេខ E ភូមិក្រាំអង្រ្គង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**<u>សូមគោរពចូលមក</u>**
**លោកមេធាវី លឹម ច័ន្ទប៊ុនកែវ**
**សមាជិកគណៈមេធាវី**

**កម្មវត្ថុ** : សំណើសុំប្តូរទៅធ្វើកម្មសិក្សាជាមួយលោកមេធាវី **រស់ ផល្លា** វិញ ។

**មូលហេតុ** : ដើម្បីជាការផ្លាស់ប្តូរបទពិសោធន៍ការងារ ។

តបតាមកម្មវត្ថុ និងមូលហេតុខាងលើ ខ្ញុំបាទមានកិត្តិយសសូមទទួលការអនុញ្ញាតពីសំណាក់លោកមេធាវីដើម្បីបញ្ចប់ការធ្វើកម្មសិក្សានៅក្នុងការិយាល័យ **ក្រុមមេធាវីអង្គរ** មកធ្វើកម្មសិក្សាជាមួយលោកមេធាវី **រស់ ផល្លា** វិញ ក្នុងគោលបំណងផ្លាស់ប្តូរបទពិសោធន៍ការងារមួយចំនួន ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម លោកមេធាវី មេត្តាអនុញ្ញាតដោយក្តីអនុគ្រោះ ។

សូម លោកមេធាវី មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦

**ហត្ថលេខា និងត្រា**

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.រឿន ពិសី

**បានឃើញ និងឯកភាពតាមសំណើ**
និងបញ្ជូនមកលោកប្រធានគណៈមេធាវីដើម្បី
ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ-សម្រេច ។
រាជធានីភ្នំពេញ ថ្ងៃទី 20 ខែ មករា ឆ្នាំ ២០១៥

**ហត្ថលេខា និងត្រា**

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.លឹម ច័ន្ទប៊ុនកែវ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំធ្វើកម្មសិក្សា

ខ្ញុំបាទឈ្មោះ **រឿន ពិសី** ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ ១១៣៩T មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ ៣៨E ផ្លូវលេខ E ភូមិក្រាំងអង្រ្គង សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

**សូមគោរពចូលមក**
**លោកមេធាវី រស់ ផល្លា**
**សមាជិកគណៈមេធាវី**

**កម្មវត្ថុ** : សំណើសុំលោកមេធាវីធ្វើជាគ្រូកម្មសិក្សា ។

**យោង** : លិខិតចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ របស់លោកមេធាវី **លឹម ច័ន្ទប៊ុនកែវ** ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **លោកមេធាវី** មេត្តាជ្រាបថាៈ កន្លងមកខ្ញុំបាទបានធ្វើកម្មសិក្សានៅក្នុងការិយាល័យ **ក្រុមមេធាវីអង្គរ** ក្រោមការដឹកនាំរបស់លោកមេធាវី **លឹម ច័ន្ទប៊ុនកែវ** ។ ដូច្នេះដើម្បីផ្លាស់ប្តូរបទពិសោធន៍ការងារមួយចំនួន ខ្ញុំបាទសុំធ្វើកម្មសិក្សាជាមួយលោកមេធាវីវិញ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកមេធាវី** មេត្តាអនុញ្ញាតឱ្យខ្ញុំបាទបានមកបំពេញកម្មសិក្សាជាមួយលោកដោយក្តីអនុគ្រោះ ។

សូម **លោកមេធាវី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**មេធាវី.រឿន ពិសី**

បានឃើញ និងឯកភាពតាមសំណើ
និងបញ្ជូនមកលោកប្រធានគណៈមេធាវីដើម្បី
ដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ-សម្រេច ។
រាជធានីភ្នំពេញ , ថ្ងៃទី 18 ខែ មករា ឆ្នាំ ២០១៦

ហត្ថលេខា និងត្រា

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី.រស់_ផល្លា